# «អ្នកមិនអាចកម្ទេចមនុស្សឡើយ»

*សាស្រ្តាចារ្យ ដេវីដ សេហុហ៊ឺ*

*ថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

រយៈពេលមួយសប្តាហ៍ នៃដំណើរការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលនៅក្នុងអង្គជំនុំជម្រះសេចក្តីប្រឆាំង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) បានចាប់ផ្តើមបន្តទៀតនៅថ្ងៃនេះ ដោយមានការធ្វើសេចក្តីសន្និដ្ឋានដែលមានរយៈពេលវែងពីសំណាក់មេធាវីជាតិ និងអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមដែលមានជនរងគ្រោះចំនួនសរុបប្រមាណ ៩០នាក់ ។ នៅក្នុងសាលសាធារណៈរបស់អង្គសវនាការពោរពេញទៅដោយប្រជាជនខ្មែរយ៉ាងច្រើនកុះករ ដែលជាអ្នកតាមដានដំណើរការរបស់តុលាការរួមមានជនរងគ្រោះរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងជនជាតិបរទេសមួយក្រុមតូចផងដែរ ។ ជាមួយគ្នានេះ ក្រុមតំណាងឲ្យប្រជាជនស៊ីវិល និងក្រុមអ្នកកាសែតអន្តរជាតិ ក៏មានវត្តមានយ៉ាងច្រើនកុះករផងដែរ ។ លោកស្រី ខារ៉ូល រ៉ូដឡៃ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក រួមជាមួយនឹងនាយករងនៃគណៈកម្មាការរបស់លោកស្រី ក៏មានវត្តមានចូលរួមក្នុងរយៈពេលប៉ុន្មានម៉ោងដំបូងរបស់ដំណើរការធ្វើសេចក្តីសន្និដ្ឋាននេះដែរ ។ ដំណាក់កាលចុងក្រោយនៃអង្គជំនុំជម្រះជាលក្ខណៈប្រវត្តិសាស្រ្តនេះ បានចាប់ផ្តើមដំណើរការដោយបទបង្ហាញដ៏គួរឲ្យចាប់អារម្មណ៍ពីប្រយោជន៍របស់តុលាការនេះ ដែលបំរើជូនប្រជាជនក្នុងស្រុក និងសកលលោក ។

ឌុច បានចូលមកដល់បន្ទប់សវនាការក្នុងសម្លៀកបំពាក់អាវកវែងពណ៌លឿងជាមួយនឹងខោពណ៌ ស ។ នៅក្នុងដំណើរការតុលាការនាពេលរសៀល ឌុច បានពាក់អាវពណ៌ស ។ ឌុច អង្គុយនៅចំកណ្តាលបន្ទប់សវនាការទល់មុខនឹងចៅក្រម ដោយមេធាវីការពារក្តីអង្គុយនៅខាងស្តាំ ហើយសហព្រះរាជអាជ្ញា និងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅខាងឆ្វេង ។ ឌុច បានរក្សាភាពស្ងប់ស្ងាត់ពេញមួយថ្ងៃដោយភាគច្រើនចំណាយពេលកត់ត្រា មើលកញ្ចក់កុំព្យូទ័ររបស់ខ្លួន និងពេលខ្លះងាកមើលទៅកាន់មេធាវីដែលធ្វើបទចោទប្រកាន់ប្រឆាំងខ្លួននៅខាងឆ្វេងដៃ ។ ប៉ុន្តែនៅពេលដែល ហ៊ីលីព កាណុន មេធាវីជាតិបារាំងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី និងសហមេធាវីរបស់លោកគឺ ម៉ាទីន ហ្សាកកាំង បានធ្វើសេចក្តីថ្លែងការណ៍ដ៏ល្អ ប្រកបដោយចំណុចសំខាន់ៗសម្រាប់ថ្ងៃនេះ ឌុច សម្លឹងមិនដាក់ភ្នែកទៅកាន់

មេធាវីទាំងពីរក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីទាំងពីររូបនេះ ដែលធ្វើឲ្យខ្ញុំងឿងឆ្ងល់ថាតើខ្ញុំកំពុងតែតាមដានមើលជនដែលមានវិប្បដិសារី ឬមនុស្សរឹងទទឹងខណៈពេលដែលពេលវេលាកំពុងតែរំកិលទៅមុខ ។

ក្នុងអំឡុងពេលសំរាកពីរលើកនេះ ឌុច បានដើរក្បែររបាំងកញ្ចក់ និងបង្ហាញក្រដាសមួយសន្លឹកសរសេរដោយដៃ ។ ប្រជាជនខ្មែរខ្លះដែល ឌុច ប្រហែលជាស្គាល់ (មិនប្រាកដ) បានរង់ចាំមើល ឌុច រួចហើយញញឹមនៅពេលដែលប្រជាជនទាំងនោះអានអត្ថន័យក្នុងក្រដាសនោះ ។ ឌុច បានដកក្រដាសចេញពីកញ្ចក់ ញញឹមរួចក៏ដើរចេញទៅហើយសើច ។ ជនជាតិបរទេសម្នាក់បានសរសេរសារលើក្រដាសមួយរួចដាក់នឹងកញ្ចក់ឲ្យ ឌុច អាន ។ អ្នកទាំងពីរញញឹមដាក់គ្នាហើយ ឌុច បានសម្តែងការរាក់ទាក់ដាក់ជនជាតិបរទេសម្នាក់នោះ រួចហើយក៏វិលទៅកាន់ទីកន្លែងអង្គុយរបស់ខ្លួនវិញ ។ រឿងប្លែកៗបានកើតឡើងនៅក្នុងបន្ទប់សវនាការ ប៉ុន្តែសកម្មភាពបែបនេះបង្កជាភាពរំខានយ៉ាងខ្លាំង ជាពិសេសប្រសិនបើយើងពិចារណាពីអត្ថន័យនៃបទចោទប្រកាន់ និងអារម្មណ៍នៃសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងថ្ងៃនេះ ។

សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មានលក្ខណៈសំខាន់ខុសប្លែកគ្នាទាំងខ្លឹមសារ និងរបៀបធ្វើសេចក្តីសន្និដ្ឋាន ។ វិធានទី២៣នៃវិធានផ្ទៃក្នុងចែងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងអង្គជំនុំជម្រះសេចក្តីក្នុងគោលបំណងគាំទ្របទចោទប្រកាន់របស់ព្រះរាជអាជ្ញា និងដើម្បីអនុញ្ញាតឲ្យជនរងគ្រោះស្វែងរកនូវសំណងថ្លៃខូចខាតតាមបែបសីលធម៌ និងសំណងថ្លៃខូចខាតរួម ។ ប៉ុន្តែសម្រាប់ថ្ងៃនេះសេចក្តីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះ មិនមែនតែងតែមានន័យដូច្នោះរហូតនោះទេ ។ លោកប្រធាន និល ណុន បានចាប់ផ្តើមអង្គជំនុំជម្រះនាពេលរសៀលដោយរំលឹកដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា មេធាវីទាំងអស់ត្រូវតែកំណត់សេចក្តីសន្និដ្ឋានរបស់ខ្លួនឲ្យស្របទៅតាមការកំណត់របស់វិធានទី២៣ ហើយក្រោយមកមេធាវីក្រុម១ និងក្រុម២បានចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋាន ។ លោកប្រធានបានមានប្រសាសន៍ថា អង្គជំនុំជម្រះនាពេលព្រឹកបានដំណើរការដោយឃ្លាតឆ្ងាយពីការកំណត់របស់ចៅក្រម ។ យ៉ាងណាមិញ សេចក្តីសន្និដ្ឋាននាពេលរសៀលភាគច្រើនបានគោរពទៅតាមសេចក្តីបង្គាប់របស់ចៅក្រម ។ បើគិតពីរយៈពេលដែលប្រគល់ឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដើម្បីរៀបចំសម្រាប់ការយកចិត្តទុកដាក់ពីប្រយោជន៍ និងតម្រូវការរបស់កូនក្តីដើម្បីស្វែងរកនូវដំណោះ

ស្រាយជាក់លាក់មួយនោះ ខ្ញុំពិតជាមានភាពភ្ញាក់ផ្អើលដែលមេធាវីខ្លះមិនបានត្រៀមចំណុចសំខាន់របស់ខ្លួន និងមិនបានធ្វើឲ្យសេចក្តីសន្និដ្ឋានរបស់ខ្លួនមានប្រសិទ្ធិភាពឡើយ ។

**ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ការីម ខាន សហព្រះរាជអាជ្ញាជាតិអន្តរជាតិអង់គ្លេសដែលមានបទពិសោធន៍បានថ្លែងនូវសេចក្តីថ្លែងការណ៍ដំបូងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដែលមានចំនួន៣៧នាក់ ។ ភាគច្រើន ការីម ខាន មិនសូវបានចូលរួមនៅក្នុងអង្គជំនុំជម្រះសេចក្តីប្រឆាំង ឌុច ទេ ហើយក៏មិនសូវបានទទួលស្គាល់ការងាររបស់សហសេវិករបស់លោករួមមាន អាឡាំង វែនណឺ មកពីប្រទេសស៊ុសហ្ស៊ីឡែន (អវត្តមានក្នុងថ្ងៃនេះ) ប្រាយអ៊ិន ម៉ាក់ហ្គូនីហ្គល មកពីសហរដ្ឋអាមេរិក និង ទី ស្រ៊ីនណា មេធាវីជនជាតិខ្មែរដែលមានវត្តមានអង្គុយក្បែរ ការីម ខាន នៅឯតុវេទិកា ។ ការីម ខាន បាននិយាយទៅកាន់ចៅក្រមដោយសេចក្តីគោរព និងបានថ្លែងសេចក្តីថ្លែងការណ៍ដ៏ល្អ ។ លោកបានទទួលស្គាល់ថា នៅក្នុងអង្គសវនាការនេះមានសមិទ្ធផលសម្រេចជាលើកដំបូងយ៉ាងច្រើន ដែលក្នុងនោះរួមមានអង្គជំនុំជម្រះដែលមានលក្ខណៈអន្តរជាតិដំបូងបង្អស់ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសេចក្តី ។ លោកបានពន្យល់ប្រាប់ថា បើទោះបីជាមានកំហុសឆ្គង ឬចំណុចខ្វះខាតណាមួយបានកើតឡើងពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការជំនុំជម្រះសេចក្តីយ៉ាងណាក្តី ក៏កិច្ចការរបស់មេធាវីទាំងអស់នេះបានធ្វើឡើងដោយជំនឿទុកចិត្តល្អ និងគោលបំណងដ៏ស្មោះត្រង់ ដើម្បីជួយឲ្យប្រព័ន្ធការងារដំណើរការទៅមុខបានល្អដូចដែលប្រជាជនកម្ពុជា និងអង្គការសហប្រជាជាតិរំពឹងទុក ។

ការីម ខាន បានសង្កត់ធ្ងន់ថា តម្រូវការត្រូវតែបែងចែករវាងរឿងពិត និងមិនពិត ។ លោកបានកត់សម្គាល់ពីបទចោទប្រកាន់ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យគំនុំ ឬជម្លោះឈាមកើតមានឡើងក្នុងអង្គជំនុំជម្រះសេចក្តី ។ មេធាវីការពារក្តីបានអះអាងទាក់ទិននឹងបញ្ហានេះដោយនិយាយថា «យើងទាំងអស់គ្នាកំពុងតែស្ថិតនៅក្នុងបន្ទប់សវនាការ មិនមែននៅឯទីផ្សារដែលយើងកំពុងតែគប់ដុំថ្ម ទៅកាន់ជនត្រូវចោទនោះទេ» ។ ប៉ុន្តែលោក ការីម ខាន បាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មិនមានទំនោរទៅតាមនិន្នាការមូលដ្ឋានសំខាន់នៃការចងគំនុំឡើយ ។ ផ្ទុយទៅវិញ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានគោរពសរសើរចំពោះនីតិវិធីរបស់អង្គជំនុំជម្រះ ដើម្បីឲ្យមេធាវីទាំងអស់អាចទទួលបាននូវភាពអស់ចិត្ត និងទទួលបានការពិត ទាក់ទិននឹងរឿងរ៉ាវដែលបានកើតមានឡើងនៅក្នុងគុកទួលស្លែង ។

បន្ទាប់មកទៀត ការីម ខាន បាននិយាយថា មេធាវីការពារក្តីបានផ្តល់យោបល់ថា «មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនខុសពីព្រះរាជអាជ្ញាប៉ុន្មានទេ» ។ លោកបានសង្កត់ធ្ងន់ថា វិធានទី២៣បានដាក់កម្រិតលើវិសាលភាពនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ លោកក៏បានអះអាងថា «យើងមិនបានធ្វើតាមសហព្រះរាជអាជ្ញាដោយមិនគិតពិចារណានោះទេ» ។ ជាក់ស្តែង លោកបានធ្វើការរៀបចំទុកផ្ទាល់ខ្លួនរបស់លោក ទាក់ទិននឹងទ្រឹស្តីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួមរបស់ព្រះរាជអាជ្ញាដែលមាននៅក្នុងសំណុំរឿងសំខាន់ៗ ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនបានដាក់ជូនឯកសារដើម្បីគាំទ្រទ្រឹស្តីនេះទេ ។

ការីម ខាន បានអះអាងថា អង្គជំនុំជម្រះសេចក្តីនេះមិនមែនទាក់ទិនតែពីភាពមានទោស និងគ្មានទោសរបស់ ឌុច នោះទេ ។ អត្ថប្រយោជន៍មួយដែលទទួលបានក្រៅពីការចូលរួមតាមដានរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រៅពីដំណោះស្រាយសម្រាប់សំណងថ្លៃខូចខាត) នោះគឺថា វាអនុញ្ញាតឲ្យជនរងគ្រោះមកប្រឈមមុខជាមួយចៅក្រម ដើម្បីផ្តល់ជាការយល់ដឹងពីឥទ្ធិពលរបស់ឧក្រិដ្ឋកម្មដែលមានមកលើជីវិតរបស់ជនរងគ្រោះទាំងអស់ ។ នោះហើយគឺជាទស្សនៈយល់ដឹងតែមួយគត់ ដែលមានតែជនរងគ្រោះទេទើបអាចផ្តល់ឲ្យបាន ។ ការតវ៉ារបស់មេធាវីការពារក្តីដែលថាដើមបណ្តឹងរដ្ឋប្បវេណីបង្កើតឲ្យមានវិសមភាពរវាងភាគីនៅក្នុងអង្គសវនាការនោះ បានបង្កឲ្យមានសេចក្តីជំទាស់ដ៏ខ្លាំងក្លាពី ការីម ខាន ។ លោកបានបដិសេធចំពោះការចោទប្រកាន់ដែលថា ឌុច បានប្រឈមមុខតតាំងជាមួយនឹងព្រះរាជអាជ្ញាចំនួនប្រាំនាក់ ។ លោកបាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនព្រះរាជអាជ្ញាទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់ឧបត្ថម្ភពីតុលាការឡើយ ។ នេះគឺជារឿងពិត បើទោះបីជាវិធានមូលដ្ឋានដែលមាននៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិចែងថា សិទ្ធិទាំងអស់ត្រូវតែផ្តល់ឲ្យប្រកបដោយប្រយោជន៍ និងប្រសិទ្ធិភាព និងមិនមែនមានភាពមិនពិតប្រាកដជាក់លាក់នោះទេ ។ ការីម ខាន បាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីមានការខ្វះខាតនូវធនធានដែលព្រះរាជអាជ្ញា និងមេធាវីការពារក្តីទទួលបានដោយផ្តល់ជាយោបល់ថា វិសមភាពគឺជាកត្តាមួយដែលមិនបានផ្តល់នូវការផ្លាស់ប្តូរដែលមានលក្ខណៈគ្រប់គ្រាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ផ្ទុយទៅវិញបែរជាបង្កើតអំណាចបំរើជាប្រយោជន៍ដល់មេធាវីការពារក្តី ។

ការីម ខាន បានសន្និដ្ឋានបញ្ចប់សេចក្តីថ្លែងការណ៍ជាលើកដំបូងរបស់លោក ដោយធ្វើការរំលឹកដល់ចៅក្រមថា ការទទួលស្គាល់បទចោទប្រកាន់មួយចំនួនរបស់ ឌុច បានបញ្ជាក់ថា បទចោទប្រកាន់ទាំង

នោះត្រូវតែបញ្ជាក់អះអាងនៅចំពោះមុខចៅក្រម ។ លោកបាននិយាយថា ចៅក្រមត្រូវតែពិនិត្យមើលភស្តុតាងដោយសត្យានុម័ត ថាតើអ្វីដែល ឌុច បានទទួលស្គាល់ទាំងស្មុគស្មាញទាំងស្រុងនោះជាការពិត ឬយ៉ាងណា ។ លោកបានបន្តទៀតថា នៅពេលដែលភស្តុតាងទាំងអស់ត្រូវបានពិនិត្យមើលសារជាថ្មីនោះ ភស្តុតាងទាំងនោះនឹងបញ្ជាក់ជាសេចក្តីសន្និដ្ឋានតែមួយគត់គឺ ៖ ជាទូទៅសម្រាប់ហេតុការណ៍ដ៏សំខាន់គឺថា ឌុច បានព្យាយាមគេចវេស និងបង្រួមតួនាទីរបស់ខ្លួនឲ្យកាន់តែតូច ។

បន្ទាប់មកទៀត ទី ស៊្រីនណា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរបានក្រោកឈរធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ។ ខណៈពេលដែល ទី ស៊្រីនណា បានចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋាន ព្រះសង្ឃចំនួនបីអង្គស្លៀកស្បង់ចីពរពណ៌លឿងបានដើរចូលក្នុងសាលសាធារណៈ ដែលធ្វើឲ្យកញ្ញារៀបចំសេចក្តីថ្លែងការណ៍របស់ខ្លួនដោយសេចក្តីគួរសម ។ ទី ស៊្រីនណា បានរៀបរាប់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការស្វែងរកការពិតនៃឧក្រិដ្ឋកម្មទាំងនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងទទួលរងនូវភាពឈឺចាប់ផ្នែកសតិអារម្មណ៍យ៉ាងខ្លាំងអស់មួយជីវិតរបស់គេ ។ ប្រសិនបើគ្មានការចូលរួមតាមដានរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេនោះ ចៅក្រមអាចនឹងប្រឈមមុខនឹងផលវិបាកក្នុងការវាស់វែងពីទំហំឧក្រិដ្ឋកម្ម និងភាពឈឺចាប់ដែលកើតមាននៅមន្ទីរស-២១ ។ គោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺស្វែងរកយុត្តិធម៌សម្រាប់ខ្លួនគេ និងសម្រាប់សមាជិកគ្រួសារជាទីស្រឡាញ់របស់គេ ។ ទិសដៅរបស់តុលាការ គឺជួយឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានភាពធូរស្បើយពីទុក្ខសោក និងការឈឺចាប់ ។

ដោយសារតែជនរងគ្រោះផ្ទាល់របស់មន្ទីរស-២១ មិនត្រូវបានប្រាប់ពីបទល្មើសរបស់គេ នៅពេលដែលត្រូវបានចាប់ខ្លួននោះ អង្គជំនុំជម្រះបានផ្តល់ជាឱកាសដើម្បីស្វែងរកការពិត និងធានាថា យុត្តិធម៌នឹងត្រូវសម្រេចបាន ។ តើហេតុអ្វីបានជាជនរងគ្រោះទាំងនោះត្រូវចាប់ខ្លួន? ជាមួយគ្នានេះ អង្គជំនុំជម្រះនេះ ក៏មានកិច្ចការដែលត្រូវប្រតិបត្តិជាច្រើនទាក់ទិននឹងការផ្សះផ្សារជាតិផងដែរ ។

បន្ទាប់មកទៀត ទី ស៊្រីនណា ក៏បានបន្តរៀបរាប់ពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងក្រុម១ និងពីជនរងគ្រោះរបស់គុកទួលស្លែងដែលកញ្ញាបានធ្វើជាតំណាងឲ្យ ។ សេចក្តីរៀបរាប់ជាច្រើនរបស់កញ្ញា បានបញ្ជាក់ជូនរួចម្តងហើយក្នុងអំឡុងពេលធ្វើសក្ខីកម្មរបស់សាក្សីការពីមុនៗ ។ កញ្ញាបានចំណាយពេលយ៉ាងយូរដែលកញ្ញាបានស៊ីពេលមួយភាគធំដែលប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ហើយក៏បង្ខំឲ្យរៀបរាប់តែឈ្មោះជនរងគ្រោះដោយគ្មានការរៀបរាប់លម្អិតបន្ថែមទៀតឡើយ ។

ការផ្សាកទៅពិភាក្សាជាមួយក ការីម ខាន បានបញ្ជាក់ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនបានរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ខ្លួនដោយយកចិត្តទុកដាក់តាមពេលវេលាដែលកំណត់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ឡើយ ។ បរិយាកាសនៃការខ្វះខាតរបៀបរៀបរយនេះបានចាប់ផ្តើមបញ្ចប់ ។ ទី ស្រ៊ីនណា បានបញ្ចប់សេចក្តីសន្និដ្ឋានភ្លាមៗ ដោយសេចក្តីបញ្ជាក់សំខាន់ៗថា ឯកសារជាច្រើនដែលបញ្ជាក់ពីទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់ត្រូវបានបំផ្លាញក្នុងអំឡុងរបបខ្មែរក្រហម និងនៅក្នុងចន្លោះឆ្នាំក្រោយរបបនេះ ។ កញ្ញាបាននិយាយថា ចំណុចនេះបានពន្យល់ប្រាប់ពីផលវិបាកខ្លះៗក្នុងការឆ្លើយតបនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីស្តីពីរឿងរ៉ាវពិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ការីម ខាន បានក្រោកឈរតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ម្តងទៀត ដោយថ្លែងនូវសេចក្តីថ្លែងការណ៍ដែលមានរយៈពេលជិត២០នាទី ។ នេះប្រហែលជាសេចក្តីសន្និដ្ឋានមួយ ដែលលោកប្រធាន និល ណុល បានគិតទុកមុននៅក្នុងចិត្តដោយក្រោយមកលោកប្រធានក៏បានក្រើនរំលឹកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យគោរពទៅតាមព្រំដែនកំណត់របស់វិធានទី២៣ ។ ការីម ខាន មានគោលបំណងប្រើប្រាស់ជំនាញដ៏ប៉ិនប្រសប់របស់លោកចោទប្រកាន់ផ្ទាល់ទៅកាន់ ឌុច ហាក់បីដូចជាលោកកំពុងតែដើរតួដូចព្រះរាជអាជ្ញា ។ បើទោះបីជាការគាំទ្រព្រះរាជអាជ្ញា គឺផ្នែកមួយនៃទិសដៅរបស់វិធានទី២៣ក៏ដោយក៏ចៅក្រមទំនងជាមិនហ៊ានចាត់ទុកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា កំពុងតែនិយាយឈានចូលកាន់តែជ្រៅទៅក្នុងបញ្ហាពិរុទ្ធភាពរបស់ជនត្រូវចោទឡើយ ។

ការីម ខាន បានលើកឡើងពីបញ្ហាទាក់ទិននឹងការអះអាងរបស់ ឌុច ដែលថា ឌុច គ្មានអំណាចឯករាជ្យនៅមន្ទីរស-២១ទេ ប៉ុន្តែ ឌុច គ្រាន់តែជាឧបករណ៍មួយតែប៉ុណ្ណោះ ។ គួរឲ្យកត់សម្គាល់ផងដែរថា មន្ទីរស-២១នេះ គឺជាជំរំសម្លាប់មនុស្សមួយកន្លែងដែល ឌុច បានដឹកនាំ ។ ឌុច មិនបានប្រើប្រាស់អំណាចឯករាជ្យរបស់ខ្លួន ដើម្បីធ្វើឲ្យភាពឈឺចាប់មានលក្ខណៈធូរស្បើយឡើយ ។ លោកបានអះអាងថា "អ្នកមិនបានដើរតួដូច Schindler ដែលជួយមនុស្សឡើយ" ។ ឌុច ជាបុគ្គលហ៊ានលះបង់ចំពោះការងារ ។ លោកបាននិយាយថា ប៉ុន្តែអ្វីដែល ឌុច អាចសម្រេចបានមិនបានកំណត់ទៅតាមមន្ទីរស-២១ឡើយ ។ យុទ្ធិធានាការនៃភាពព្រឺខ្លាច និងការធ្វើទារុណកម្មដែល ឌុច បានប្រតិបត្តិនៅក្នុងមន្ទីរស-២១ មានឥទ្ធិពលបង្កឲ្យមានភាពភ័យរន្ធត់កាន់តែច្រើនឡើងគ្រប់ទីកន្លែងនៅក្នុងបក្ស ។ មន្ទីរស-២១ បានបង្កើតឲ្យមានជាកង់ដ៏សាហាវមួយ ដែលការចាប់ខ្លួនមនុស្សបានកើតមានឡើងជាបន្ត

បន្ទាប់ ហើយមនុស្សជាច្រើនទៀតត្រូវបានទទួលរងទារុណកម្ម ហើយបង្ខំឲ្យមានចម្លើយសារភាពខុសពីការពិត ដែលមានជាប់ពាក់ព័ន្ធនឹងមនុស្សដទៃធ្វើឲ្យកង់នេះវិលសារជាថ្មីម្តងទៀត។ ឌុច បានបំពេញកិច្ចការទាំងអស់នេះពីព្រោះថា ឌុច មានគោលគំនិតផ្នែកមនោគមវិជ្ជាដូចគ្នានឹងមេដឹកនាំរបស់ខ្លួន។ ហេតុផលគឺមិនមែន ដោយសារតែ ឌុច មានបំណងចង់ក្លាយជាក្រុមមនុស្សដែលមានអំណាចតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ដោយសារតែការធ្វើបែបនេះអាចជួយឲ្យជីវិតរបស់ ឌុច មានភាពសុខស្រួល។ ការីម ខាន បាននិយាយថា ភស្តុតាងបាននិយាយប្រាប់ពីរឿងរ៉ាវទាំងនេះដោយខ្លួនឯង។ ខណៈពេលដែល ឌុច មានជម្រើសដោះលែងអ្នកទោសក្នុងអំឡុងពេលវឹកវរដោយសារតែការលុកលុយរបស់កងទ័ពវៀតណាមនោះ ឌុច បែរជាសម្លាប់អ្នកទោសទាំងអស់នោះទៅវិញ។ ឌុច បានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនតាំងពីនៅវិទ្យាល័យ ហើយ ឌុច បានធ្វើកិច្ចការនេះនៅឯមន្ទីរស-២១ ដោយឆន្ទៈខ្លួនឯង។ ឌុច មានជំនឿទុកចិត្តគ្រប់គ្រាន់ក្នុងការរាយការណ៍ជូនមេដឹកនាំខ្មែរក្រហម ដែលចេញសេចក្តីសម្រេចដោយគ្មានការគិតពិចារណាតាមសេចក្តីស្នើសុំរបស់ ឌុច។ បើទោះបីជាមេធាវីការពារក្តីព្យា-យាមបង្រួមតួនាទីរបស់ ឌុច ក៏ដោយ ក៏ ឌុច នៅតែអាក់ខានមិនបានចាប់យកឱកាសនោះ ដែលអាចនឹងបង្រួមតួនាទីរបស់ខ្លួនដែរ។ គ្មានឯកសារណាមួយដែលណែនាំ ឌុច ពីទម្រង់បែបបទធ្វើទារុណកម្មនោះទេ ប៉ុន្តែ ឌុច បានច្នៃប្រឌិតប្រព័ន្ធធ្វើទារុណកម្មដ៏សាហាវនិងគ្មានមេត្តានោះនៅមន្ទីរម-១៣ ហើយបន្ទាប់មកទៀតនៅមន្ទីរស-២១ដោយខ្លួនឯង។ ឌុច បានអះអាងថា ខ្លួនបានដាក់អ្នកទោសនៅក្នុងរណ្តៅនៅឯមន្ទីរម-១៣ ដើម្បីការពារអ្នកទោសទាំងនោះពីការវាយប្រហារផ្លូវអាកាសរបស់អាមេរិក ដែលតាមការពិតការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសនេះបានបញ្ចប់រួចទៅហើយនោះ។ ការីម ខាន បាននិយាយថា ទម្រង់បែបបទនៃទារុណកម្មបានលេចឡើង ខណៈពេលដែល ឌុច ព្យាយាមផ្លាស់ប្តូរ និងបង្រួមតួនាទីរបស់ខ្លួនដោយឥរិយាបថឥតអៀនខ្មាស់ជាទីបំផុត។ ឌុច មិនបានដាក់វិន័យដល់អ្នកយាមគុកដែលបានបញ្ឆោឲ្យអ្នកទោសស៊ីលាមកខ្លួនឯង។ លោកបានអះអាងថា វាពិតជាមិនសមហេតុផលទាល់តែសោះដែល ឌុច បានប្រាប់អ្នកសួរចម្លើយឲ្យបង្ខំអ្នកទោសគូររូបសត្វឆ្កែរួច ហើយគោរពសត្វឆ្កែក្នុងគោលបំណងបង្កជាជោគវាសនាដ៏អាក្រក់ដល់អ្នកទោស។

ការីម ខាន បានលើកឡើងពីចំណុចសំខាន់បន្ថែមទៀតថា ប្រសិនបើយើងប្រៀបធៀបអ្វីដែល ឌុច បានទទួលស្គាល់ទាំងស្ទាក់ស្ទើរនៅក្នុងអង្គសវនាការជាគំរូនៃការពិត និងការផ្សះផ្សារនោះ បើទោះបីជា ឌុច បានបង្ហាញវិប្បដិសារីតែមួយផ្នែកតូចក៏ដោយ ក៏ការលើកលែងទោសសម្រាប់យន្តការបែបនេះត្រូវផ្តល់ឲ្យបានលុះត្រាតែសាក្សីនោះបានរៀបរាប់ពីការពិត និងបង្ហាញពីវិប្បដិសារីឲ្យមានលក្ខណៈ

ពេញលេញ ។ លោកបានសូមក្រើនរំលឹកចៅក្រមឲ្យ «ឈ្វេងយល់» ចំពោះការពិតដែលថា ឌុច មិនមាន លក្ខណៈពេញលេញដែលតម្រូវទៅតាមបទដ្ឋានលើកលែងនោះឡើយ ។ លោកបានបន្តទៀតថា យុត្តិសាស្ត្ររបស់ ឌុច គឺធ្វើយ៉ាងណាឲ្យចៅក្រមជឿតែប៉ុណ្ណោះ ។ ការីម ខាន បានបញ្ចប់សេចក្តីសន្និដ្ឋាន ដោយស្នើឲ្យចៅក្រមធ្វើការពិចារណាលើភស្តុតាងដោយប្រុងប្រយ័ត្នបំផុត ដោយគូសបញ្ជាក់ថា ការពិត មិនទាមទារដាទឹកប្រាក់ក្នុងសំណាងថ្លៃខូចខាតឡើយ ។ ប៉ុន្តែការពិតមានតម្លៃដ៏ធំធេងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោកបានស្នើសុំឲ្យចៅក្រមចេញសេចក្តីសម្រេចថា ឌុច មានទោសតាមបទចោទប្រកាន់ ។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២

ក្រោយពីការពន្យាពេលរយៈពេលខ្លី ស៊ីលឃិ ស្តូតហ្វិនស្តិ មកពីប្រទេសអាឡឺម៉ង់បានរៀបរាប់ថា លោកស្រី គឺជាមនុស្សម្នាក់ដែលរស់នៅជាមួយនឹងអតីតកាលរបស់ប្រទេសអាឡឺម៉ង់ ។ នៅនូរិមប៊ឺក អំពើសាហាវឃោរឃៅបានបន្តកើតមានឡើងចាប់តាំងពីសង្គ្រាមលោកលើកទី២ ។ លោកស្រីជឿថា អង្គជំនុំជម្រះសេចក្តីប្រឆាំង ឌុច នឹងអាចបញ្ចប់និទ្ទណ្ឌភាពមួយចន្លោះនៅក្នុងប្រវត្តិថ្មីៗនេះដែលកើតមានឡើងតាំងពីរបបខ្មែរក្រហម ។ លោកស្រីនិងក្រុមការងាររបស់លោកស្រីបានធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ដែលមានចំនួន១៧នាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែធ្វើការដោះស្រាយពីអត្ថន័យចំពោះរឿងរ៉ាវដែលបានកើតឡើងជារៀងរាល់ថ្ងៃ ។ ហេតុអ្វីបានជាអ្នកទោសទាំងនោះត្រូវជ្រើសរើសយកមកឃុំឃាំង និងទទួលទារុណកម្ម ខណៈពេលដែលអ្នកទោសទាំងនោះមិនមានទោសអ្វីទាំងអស់? តើអ្នកទោសទាំងនោះត្រូវសួរចម្លើយដោយនរណានិងរបៀបណា? ហេតុអ្វីបានអ្នកទោសត្រូវសម្លាប់ និងស្លាប់ដោយរបៀបណា? អង្គជំនុំជម្រះមិនអាចឆ្លើយនឹងសំណួរទាំងអស់នេះបានទេ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងនូវភាពអន្ទះអន្ទែងជាប្រចាំនៅក្នុងជីវិតរបស់គេ ទាមទារឲ្យមានការបង្ហាញនូវការពិត ។ លោកស្រីបាននិយាយថា ការបង្ហាញនូវការពិត គឺជាមធ្យោបាយតែមួយគត់ដែលបង្កើតជាសេចក្តីថ្លៃថ្នូរឲ្យដើមបណ្តឹងរដ្ឋប្បវេណីសារជាថ្មីម្តងទៀត ។ ស៊ីលឃិ ស្តូតហ្វិនស្តិ បានរៀបរាប់ពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩នាក់ ដែលលោកស្រីធ្វើជាតំណាងឲ្យ ដែលមិនមានជាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះសេចក្តី ។

បន្ទាប់មកទៀត ស៊ីលយិ ស្ទូតហ្ស៊ីនស្គី បានចាប់ផ្ដើមធ្វើការរិះគន់យ៉ាងខ្លាំងលើចៅក្រមថា ចៅក្រមធ្វើការចាត់ចែងរៀបចំក្រុមដើមបណ្ដឹងរដ្ឋប្បវេណីមិនបានល្អ ។ លោកស្រីក៏បានចោទប្រកាន់ចៅក្រមបន្ថែមទៀតថា មិនមានសេចក្ដីអាណិតអាសូរចំពោះភាពឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ លោកស្រីបានមានប្រសាសន៍ថា ពាក្យថា«អរគុណ»មានតែពីរពាក្យតែប៉ុណ្ណោះ ហើយពាក្យ ពីរពាក្យ នេះមានន័យខ្លាំងណាស់ ប៉ុន្ដែចៅក្រមមិនដែលប្រើពាក្យនេះជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ។ មានចំណាប់អារម្មណ៍តិចតួចណាស់ទាក់ទិនថា តើដើមបណ្ដឹងរដ្ឋប្បវេណីមានបញ្ហាតានតឹងផ្លូវចិត្តប៉ុណ្ណា ។ ដើមបណ្ដឹងរដ្ឋប្បវេណីតែងតែសំរានមិនលក់នៅពេលយប់មុននឹងឡើងមកធ្វើកសិណសាក្សី ហើយអ្នកទាំងនេះពិតជាព្រួយបារម្ភ និងមានទុក្ខក្រៀមក្រំយ៉ាងខ្លាំង ។ លោកស្រីបានបន្តថា គ្មានអ្នកជំនាញណាម្នាក់អាចនឹងត្រូវទទួលរងការមិនយកចិត្តទុកដាក់ដូច្នេះទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានណែនាំឲ្យទប់អារម្មណ៍របស់ខ្លួន ដូច្នេះដើមបណ្ដឹងរដ្ឋប្បវេណីក៏ខំទប់ទឹកភ្នែក និងអារម្មណ៍របស់គេទាំងបន្ទំ ។ ប៉ុន្ដែការបង្ហាញពីភាពឈឺចាប់ និងភាពតានតឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជួយបង្ហាញពីឧក្រិដ្ឋកម្មរបស់ ឌុច ហើយចៅក្រមគួរតែបានឃើញនូវភាពឈឺចាប់ទាំងនោះ ។ នៅពេលដែលជនរងគ្រោះម្នាក់ត្រូវបានណែនាំឲ្យបង្ហាញស្លាកស្នាមរបស់ខ្លួនជាសាធារណៈនៅក្នុងបន្ទប់សវនាការ មេធាវីរបស់ជនរងគ្រោះនោះបានការពារក្រុនក្ដីរបស់ខ្លួន ហើយសំណាងល្អមេធាវីក៏បានកែប្រែសំណូមពររបស់ចៅក្រម ។ ស៊ីលយិ ស្ទូតហ្ស៊ីនស្គី បានអះអាងថា ជាញឹកញាប់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតែងតែទទួលរងការរំខានពីសំណាក់លោកប្រធានចៅក្រមដែលបង្កឲ្យមានចំណាប់អារម្មណ៍ថា ចៅក្រមមិនមានចំណាប់អារម្មណ៍នឹងដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ។

ស៊ីលយិ ស្ទូតហ្ស៊ីនស្គី បានរិះគន់ កា សាវុធ មេធាវីការពារក្ដីជាតិ សម្រាប់ការពោលពាក្យប្រមាថពីដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងការរំលោភបំពានផ្លូវភេទទៅកាន់មេធាវីការពារក្ដីអន្តរជាតិ ។ លោកស្រីបានសួរថា ហេតុអ្វីបានជាដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចទទួលបាននូវការគោរពដោយស្មើភាព ។ លោកស្រីឆ្ងល់ថា «តើភាពឈឺចាប់នេះពិតជាពិបាកនឹងទទួលរងខ្លាំងណាស់ឬ? លោកស្រីបាននិយាយបន្តទៀតថា លោកប្រធានចៅក្រមគួរតែការពារប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ បើទោះបីជាមានការខ្វះខាតទាំងនេះក៏ដោយ ក៏ដើមបណ្ដឹងរដ្ឋប្បវេណីសូមកោតសរសើរចំពោះឱកាសដែលចៅក្រមបានផ្ដល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួននៅចំពោះមុខតុលាការ ។

ក្រោយពីការរៀបរាប់ពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនមក លោកស្រីបានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ដោយលើកឡើងពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលជាជនរងគ្រោះពីការរំលោភបំពានផ្លូវភេទ ។ អ្នកមីងដែលជាជនរងគ្រោះបានរស់នៅដោយភាពស្ងប់ស្ងាត់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ នេះគឺដោយសារតែនៅក្នុងប្រទេសកម្ពុជា ការលាតត្រដាងប្រាប់ថា ខ្លួនត្រូវបានគេរំលោភ ដោយចាត់ទុកថាជា«រឿងអាម៉ាស់»សម្រាប់អ្នកគ្រប់គ្នា ។ ប៉ុន្តែខណៈពេលដែលអ្នកមីងជនរងគ្រោះបានឃើញ ឌុច នៅក្នុងបន្ទប់សវនាការអ្នកមីងមិនអាចនៅស្ងៀមបានទេ ។ ប្រសិនបើការអះអាងរបស់ជនរងគ្រោះត្រូវបានបដិសេធនោះមានន័យថា គ្មានយុត្តិធម៌ទេ សម្រាប់ជនរងគ្រោះពីការរំលោភ ។

គង់ ពិសី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ បានសង្កត់ធ្ងន់លើឧក្រិដ្ឋកម្មរំលោភ និងបានរិះគន់ ឌុច ដែលលាក់បាំងការមិនយកចិត្តទុកដាក់ដោយចេតនារបស់ខ្លួនពីក្រុមព្រហ្មទណ្ឌលើឧក្រិដ្ឋកម្មនេះ ។ ការធ្វើបែបនេះគឺដូចជាការទះកម្លៀងលើមុខជនរងគ្រោះ ។ គង់ ពិសី បានអះអាងថា ឌុច មានបំណងគេចវេសពីការទទួលខុសត្រូវដោយឈ្លាសវៃនៅពេលដែលការទទួលខុសត្រូវនោះសាកសមនឹង ឌុច ។ លោកបានបន្តទៀតថា ស្ត្រីជាច្រើនបានបោកបញ្ឆោតឲ្យធ្លាក់ចូលក្នុងការបំពានលើផ្លូវភេទ ក្រោមការបញ្ជារបស់ ឌុច ។ លោកបានផ្តល់ជាឧទាហរណ៍មួយចំនួនដោយបញ្ជាក់ថា អ្នកយាមគុកបុរសធ្វើការគ្រប់គ្រងលើអ្នកទោសស្រី ។ ដោយសារតែអ្នកទោសស្រីទាំងអស់ត្រូវតែស្លាប់នោះអ្នកទោសទាំងនោះងាយស្រួលនឹងទទួលរងគ្រោះពីការរំលោភបំពានលើផ្លូវភេទណាស់ ។ ប៉ុន្តែ ឌុច បែរជាមិនបានរារាំងការរំលោភបំពានទាំងនេះ ឬដាក់ទណ្ឌកម្មលើជនដៃដល់ឡើយ ។ ជាមួយគ្នានេះ ឌុច ក៏បានអនុញ្ញាតឲ្យអ្នកយាមធ្វើឲ្យអ្នកទោសប្រុសមានភាពអាម៉ាស់ ដោយនិយាយចំអកឡកឡឺយដាក់អ្នកទោសទាំងនោះនៅពេលដែលពួកគេបានដោះខោអាវចេញអស់ក្នុងអំឡុងពេលបាញ់ទឹកសម្អាតខ្លួន ។ ការធ្វើបែបនេះ គឺជាការរំលោភបំពានផ្លូវភេទ ដែលចូលរួមចំណែកដល់ការប្រព្រឹត្តអំពើអមនុស្សធម៌ដោយបានប្រព្រឹត្តទៅលើអ្នកទោស ។

គង់ ពិសី បានបញ្ជាក់ថា ឌុច មិនមែនជាអ្នករងទោសជំនួសអ្នកដទៃឡើយ ។ ឌុច គឺជាអ្នកចូលរួមម្នាក់ដែលមានឆន្ទះ និងរីករាយជាមួយនឹងការងារដោយភាពម៉ត់ចត់បំផុត ទាក់ទិននឹងបញ្ហាស្ថានភាពនៅក្នុងគុក ។ លោកបានអះអាងថា ឌុច មិនមែនត្រឹមតែមានមោទនៈភាពចំពោះការងាររបស់ខ្លួនតែប៉ុណ្ណោះទេ ឌុច ពិតជាសប្បាយនឹងអំណាចដូចជាមនុស្សដែលស្រេកឃ្លានអំណាច ។ គោលបំណងរបស់ ឌុច គឺ

រក្សាអំណាចរបស់ខ្លួន។ ក្រោយមក ឌុច បានប្តូរមកកាន់សាសនាគ្រិស្ត ដើម្បីធ្វើឲ្យខ្លួនស្ថិតនៅក្នុងសាសនាត្រឹមត្រូវដែលមានអំណាចជាជាងធ្វើជាអ្នកកាន់សាសនាព្រះពុទ្ធ ដែលនឹងអាចត្រូវទទួលទណ្ឌកម្មធ្លាក់នរក១៨ជាន់ ដោយគ្មានសង្ឃឹមថានឹងបានចាប់ជាតិសារជាថ្មីឡើយ។ នៅក្នុងអង្គសវនាការ គង់ ពិសី បានគូសបញ្ជាក់ថា ឌុច មិនមែនជាមនុស្សស្មោះត្រង់ និងនិយាយពីការពិតទេ។ តាមពិត ការទទួលស្គាល់ពីឧក្រិដ្ឋកម្មរបស់ ឌុច គឺធ្វើឡើងដោយស្ទាក់ស្ទើរ។ មានសំណួរជាច្រើនដែល ឌុច មិនបានឆ្លើយ ឬគេចវេសមិនឆ្លើយតប។ លោកបានបន្តនិយាយទៀតថា ឌុច មិនបានគោរពតាមពាក្យសន្យារបស់ខ្លួនជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលថានឹងផ្តល់នូវការពិតនិងចម្លើយទៅកាន់សំណួរទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ការសម្តែងនូវវិប្បដិសារីនិងការសុំទោសម្តងហើយម្តងទៀតរបស់ ឌុច ត្រូវបានជំទាស់ដោយមេធាវីការពារក្តីរបស់ ឌុច។ ឌុច សម្រក់ទឹកភ្នែកក្លែងក្លាយកាលពីម៉ោង៨ ហើយទឹកភ្នែកនេះ គឺជាវិប្បដិសារីដែលប្រឌិតឡើងតែប៉ុណ្ណោះ។

គង់ ពិសី បានបញ្ចេញទស្សនៈដ៏គួរឲ្យចាប់អារម្មណ៍មួយចំនួនទាក់ទិននឹងសំណងថ្លៃខូចខាត។ ឌុច អាចសរសេរប្រវត្តិរូបផ្ទាល់ខ្លួនមួយ និងប្រើប្រាស់ប្រាក់កម្រៃដែលទទួលបានពីការនិពន្ធប្រវត្តិរូបនេះ ដើម្បីឧបត្ថម្ភដើមបណ្តឹងរដ្ឋប្បវេណី។ ឌុច អាចសរសេរប្រវត្តិរូបរបស់ខ្លួនបានខណៈពេលនៅក្នុងគុកនិងអាចប្រើប្រាស់ប្រាក់ចំណូលនោះសម្រាប់ការឧបត្ថម្ភដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាមួយគ្នានេះ គង់ ពិសី ក៏បានស្នើថា ឌុច គួរតែសរសេរសំបុត្រចំនួនពីរច្បាប់ផ្ញើរជូនរដ្ឋាភិបាល។ សំបុត្រច្បាប់ទីមួយ គួរតែជាសំបុត្រសុំទោសចំពោះរដ្ឋាភិបាល ចំណែកឯសំបុត្រច្បាប់ទីពីរគួរតែសំណូមពររដ្ឋាភិបាលថា ទឹកប្រាក់មួយភាគបីដែលទទួលបានពីការចូលទស្សនាមន្ទីរស-២១ គួរតែយកមកប្រើប្រាស់សម្រាប់សំណងថ្លៃខូចខាត។ ជាចុងក្រោយ លោកបានសន្និដ្ឋានបញ្ចប់ថា បំណងវិលចូលក្នុងសង្គមកម្ពុជាវិញរបស់ ឌុច គួរតែត្រូវបដិសេធ។

ក្រោយពីការបញ្ចប់សេចក្តីសន្និដ្ឋាន បញ្ចប់ការសួរដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២មក អង្គសវនាការបានឈប់សម្រាកសម្រាប់អាហារថ្ងៃត្រង់។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី

ហ៊ុលីព កាណុន បានថ្លែងសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលជាលើកដំបូងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ដែលមានចំនួន២៨នាក់។ លោកបានរៀបរាប់ពីបញ្ហាដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បានប្រឈមមុខដោះស្រាយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានបំពេញកិច្ចការដ៏ធំធេងរបស់ខ្លួនដោយមិនចេះនឿយហត់ដើម្បីប្រមែរប្រមូលជនរងគ្រោះទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ គឺជាកំណែប្រែថ្មីដ៏ចម្បងមួយ ។ មេធាវីគ្រប់រូបបានព្យាយាមជួយសម្រួលដល់ដំណើរការរបស់តុលាការ ដើម្បីធានាឲ្យបាននូវយុត្តិធម៌សម្រាប់អង្គជំនុំជម្រះសេចក្តីនេះ ។

ជាញឹកញាប់ប្រតិកម្មដំបូងបង្អស់របស់ដើមបណ្តឹងរដ្ឋប្បវេណីគឺកើតពីសភាវគតិរបស់គេ ៖ ឌុច ត្រូវតែទទួលរងនូវការប្រព្រឹត្តដូចគ្នាដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះបានធ្លាប់ទទួលរង ។ ហ៊ីលីព កាណុន បានណែនាំថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គួរតែបញ្ចេញទស្សនៈគាំទ្រប្រតិកម្មដំបូងនេះ ប៉ុន្តែមេធាវីទាំងអស់ត្រូវតែពុះពារដើម្បីសម្រេចគោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះយុត្តិធម៌នឹងអាចផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានមិនមែនភាពសាហាវឃោរឃៅនោះទេ ។ លោកបានដកស្រង់ពាក្យសម្តីមួយចំនួនរបស់ ឌុច ដែលបាននិយាយនៅក្នុងដំណើរការអង្គជំនុំជម្រះសេចក្តីកន្លងមកដែលពាក្យសម្តីទាំងអស់នោះបានគូសបញ្ជាក់ថា ឌុច មានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចោទនៅក្នុងដីការចោទប្រកាន់ ។ ដោយសារតែពាក្យសម្តីទាំងអស់នេះ ហ៊ីលីព កាណុន ឆ្ងល់ថាតើការភ្ញាក់ខ្លួនរបស់ ឌុច នៅក្នុងអង្គជំនុំជម្រះនេះធ្វើឡើងដោយស្មោះត្រង់ឬយ៉ាងណា ។ បើទោះបីជាការសម្រក់ទឹកភ្នែកគឺជាផ្នែកដំបូងនៃការភ្ញាក់ខ្លួនក៏ដោយ ឌុច នៅតែសុំឲ្យខ្លួនត្រូវបានដោះលែង ។ លោកបានបន្តទៀតថា "សូមមើលមកកាន់ជនរងគ្រោះទាំងអស់នេះ! ឌុច សូមសម្លឹងមើលមកជនរងគ្រោះទាំងនេះដែល ឌុច ឯងបានព្យាយាមដាក់ទណ្ឌកម្មមកលើពួកគេ ។ "អ្នកអាចវាយកម្ទេចសត្វល្អិតនិងសត្វពាហនៈបាន ។ ប៉ុន្តែអ្នកមិនអាចវាយកម្ទេចមនុស្សបានទេ ពីព្រោះថា នៅថ្ងៃណាមួយមនុស្សទាំងនេះនឹងក្រោកឈរប្រឆាំងម្តងទៀតដោយហេតុថា មនុស្សទាំងនេះ ឬក៏មានអ្នកស្នងត្រកូលរបស់គេនឹងទាមទារជំរះបញ្ជីនេះជាមិនខាន.... ។ ការសម្លឹងមើលទៅកាន់សេចក្តីស្លាប់របស់មនុស្សទាំងនេះហើយដែលនឹងកាត់ទោស ឌុច ឯងវិញ ។ ប្រហែលជាជនរងគ្រោះរបស់ ឌុច អាចនឹងអត់ឱនទោសឲ្យ ឌុច បានក្រោយពេលដែលតុលាការនេះបានបញ្ចប់ទៅ ។ សូមគិតពិចារណាថា តើជនរងគ្រោះទាំងនេះបានព្យាយាមស្វែងរក និងស្វែងយល់ថាហេតុអ្វីបានជាបុរសម្នាក់នេះបានបង្កើតភាពសាហាវព្រៃផ្សៃបែបនេះបាន ។ តើមនុស្សធម្មតាម្នាក់នេះបានទទួលការគោរពពីមនុស្សដទៃ ប៉ុន្តែក្លាយជាមនុស្សដ៏គួរឲ្យខ្លាចដោយរបៀបណា?

ហ៊ីលីព កាណុន បានក្រើនរំលឹក ឌុច ថាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះគឺជាមនុស្សស្លូតត្រង់ធម្មតា សុភាពរម្យទម ជាមនុស្សក្រីក្រ ហើយក៏មិនមែនជាមនុស្សចេះដឹងខ្ពង់ខ្ពស់ឡើយ ។ ស្របពេលគ្នានេះ អ្នកទាំងអស់កំពុងតែតស៊ូពុះពារដូចគ្នា ដើម្បីស្វែងរកច្បាប់មកធ្វើជាបង្អែកសម្រាប់ការបន្តរស់នៅក្នុងនាមជាមនុស្ស និងដើម្បីកុំឲ្យធ្លាក់ចូលទៅក្នុងស្ថានភាពជាសត្វ ។ គោលបំណងរបស់អ្នកទាំងនេះ គឺមិនមែនដើម្បីបំផ្លាញមនុស្សដើម្បីបំរើដូនមនោគមវិជ្ជានោះទេ ។ ការប្រព្រឹត្តជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដោយភាពប្រមាថមើលងាយ នឹងក្លាយជាអំពើអមនុស្សធម៌ទម្រង់បែបថ្មីមួយទៀត ។

គួរឲ្យចាប់អារម្មណ៍ផងដែរ ហ៊ីលីព កាណុន បានទទួលស្គាល់ថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានរៀបចំខ្លួនឲ្យបានរៀបរយនោះទេក្នុងអំឡុងពេលជំនុំជម្រះសេចក្តី ។ ប៉ុន្តែមេធាវីទាំងអស់បានកំពុងចាប់ផ្តើមប្រព័ន្ធអនុវត្តថ្មីសម្រាប់អង្គជំនុំជម្រះសេចក្តីប្រឆាំង ឌុច ។ ប្រសិបើអង្គជំនុំជម្រះសម្រេចឲ្យដើមបណ្តឹងរដ្ឋប្បវេណីរក្សាភាពស្ងៀមស្ងាត់ក្នុងពេលជំនុំជម្រះសេចក្តីដូចមុននោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងក្លាយជានិមិត្តរូបគ្មានសម្លេង ហើយអ្នកទាំងនេះនឹងត្រូវបានបាត់ខ្លួនវិញម្តងទៀតជាមិនខាន ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះមិនមែនជាជនរងគ្រោះនៃរឿងរ៉ាវ ដែលកើតឡើងចំពោះរូបគេនោះយើងគួរតែយល់ពីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ។ ហ៊ីលីព កាណុន បានស្មានទុកជាមុនថាប្រវត្តិសាស្ត្រនឹងត្រូវរៀបចំឡើងម្តងទៀតបានដោយសារតែជនរងគ្រោះ ។ លោកបាននិយាយថាសំណង់ថ្លៃខូចខាតដែលមានតម្លៃបំផុតនោះ គឺវត្តមានរបស់ជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះ និងការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះទាំងអស់នេះ ។

ហ៊ីលីព កាណុន មានប្រសាសន៍ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្លឹងមើលឃើញទុកជាមុននូវគម្រោងថ្មីមួយសម្រាប់តុលាការអន្តរជាតិកូនកាត់នេះ ដើម្បីជម្រុញឲ្យមានការយកចិត្តទុកដាក់ពីជនរងគ្រោះឲ្យកាន់តែប្រសើរជាងនេះ ។ លោកបានបញ្ចប់សេចក្តីសន្និដ្ឋានរបស់លោក ដោយធ្វើការរិះគន់ពីការប្រើប្រាស់កំណាព្យជាភាសាបារាំងរបស់ ឌុច ដែលមានចំណងជើងថា “ការស្លាប់របស់ឆ្កែចចក” ពីព្រោះថា ឌុច ស្វែងរកតែផ្នែកអាក្រក់នៃកំណាព្យនេះតែប៉ុណ្ណោះ ។ ឌុច មិនដែលផ្តល់ឱកាសដល់មនុស្សដូចគ្នាឡើយ ។ ដោយសារតែហេតុផលនេះហើយដែល ហ៊ីលីព កាណុន មិនយល់ពីការភ្ញាក់ខ្លួនរបស់ ឌុច ។ ហ៊ីលីព កាណុន ឆ្ងល់ថា តើ ឌុច កំពុងតែព្យាយាមបំពេរយើងទាំងអស់គ្នាឲ្យដេកលក់មែនឬទេ? តើឯណាទៅមនោសញ្ចេតនាដែលអាចមានចំពោះការស្លាប់របស់មនុស្សចំនួន ១៦.០០០នាក់ ឬក៏ច្រើនជាងនេះនៅឯគុកទួលស្លែងនោះ? លោកបាននិយាយទៅកាន់ ឌុច ខណៈ

ពេលដែលលោកបានបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់លោកថា «យើងបានចាត់ទុកថាអ្នកបានក្លាយជាសត្វចចកមួយក្បាលសម្រាប់មនុស្សជាតិ» ។

ម៉ាទីន ហ្សាកកាំង បានចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍ដ៏ក្បោះក្បាយបន្ទាប់ពី ហ៊ីលីព កាណុន ។ លោកស្រីបានរៀបរាប់ថា ជនរងគ្រោះបានចំណាយពេលអស់យ៉ាងយូរ ដើម្បីនិយាយពីរឿងរ៉ាវរបស់គេ ។ លោកស្រីបាននិយាយថា «តុលាការនេះកំពុងតែផ្តល់ឱកាសសម្រាប់ការចងចាំ» ។ តុលាការបានអនុញ្ញាតឲ្យកូនប្រុសស្រីរបស់អ្នកដែលស្លាប់បាត់បង់ជីវិតហើយនោះ ទទួលបានការដឹងព្ធពីការចងចាំរបស់គេ ។ បន្ទាប់មកទៀតលោកស្រីបានបង្ហាញពីរូបថតជនរងគ្រោះមួយចំនួន និងរូបថតអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រោយមកទៀត លោកស្រីបានមានប្រសាសន៍ថា ជនដៃដល់នៃឧក្រិដ្ឋកម្មបែបនេះមិនមែនប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ដោយសារតែមានបញ្ហាសតិអារម្មណ៍នោះទេ ។ ផ្ទុយទៅវិញ ជនដៃដល់ទាំងនេះ ទាយយកភាពសប្បាយរីករាយពីការបណ្តោយខ្លួនចូលទៅក្នុងរោគឆ្កួតឡប់ដ៏ពេញនិយមនោះ ។ នេះគឺជារឿងពិតមួយដ៏គួរឲ្យភ័យខ្លាចជាទីបំផុត ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវតែចូលខ្លួនធ្វើកសិណសាក្សី ដើម្បីឲ្យមនុស្សជាតិទាំងអស់អាចចូលរួមក្នុងគណៈកម្មាការស្វែងរកយុត្តិធម៌ ។ តាមទស្សនៈរបស់លោកស្រី ម៉ាទីន ហ្សាកកាំង ដើមបណ្តឹងរដ្ឋប្បវេណីនឹងអត់ឱនទោសឲ្យជនណាម្នាក់បានលុះត្រាតែជននោះអាចបញ្ជាក់ថាខ្លួនដឹងពីកំហុសពីអតីតកាលរបស់ខ្លួន ហើយនឹងព្យាយាមគិតពិចារណាពីកំហុសទាំងនោះដែលមាននៅក្នុងសតិអារម្មណ៍របស់អ្នកដទៃ ។ លោកស្រីបាននិយាយថា គ្មានអ្វីអាចធ្វើឲ្យមនុស្សដែលគ្រប់គ្រងលើមនុស្សដទៃទៀតទទួលបានយុត្តិធម៌បានទេ ។

ម៉ុច សុវណ្ណារី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិបានសម្តែងការដឹងគុណដល់រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិសម្រាប់ការបង្កើតតុលាការនេះឡើង ។ កញ្ញាបានផ្តោតទៅលើសំណងថ្លៃខូចខាត និងសង្កត់ធ្ងន់ពីតម្រូវការចាំបាច់ក្នុងការថែទាំសុខភាពប្រកបដោយប្រសិទ្ធិភាពជូនដល់ជនរងគ្រោះ ដែលនៅរស់រានមានជីវិត ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវការយុត្តិធម៌ ហើយយុត្តិធម៌នេះ ត្រូវតែសម្រេចឲ្យបាន ។ ជាមួយគ្នានេះ សំណងថ្លៃខូចខាតអាចនឹងជួយសម្រេចយុត្តិធម៌នេះបាន ។ ម៉ុច សុវណ្ណារីបានស្នើរជាវិធីសាស្ត្រជាច្រើនដើម្បីប្រតិបត្តិសំណងថ្លៃខូចខាតដូចជា :

១. បង្កើតជាមូលនិធិសទ្ធាស្ម័គ្រចិត្តមួយ ។

២. រក្សាការពារទីកន្លែងឧក្រិដ្ឋកម្មដែលជនរងគ្រោះត្រូវបានសម្លាប់ និងរួមទាំងឯកសារដែលនៅសេសសល់ទាំងអស់ដើម្បីឲ្យក្មេងជំនាន់ក្រោយអាចបញ្ជាប់ «កង់ប្រវត្តិសាស្ត្រដ៏គួរឲ្យខ្លាចនេះ» បាន ។
៣. រក្សាការពាររូបថតទាំងអស់ដែលដាក់តាំងនៅមន្ទីរស-២១ ។
៤. កសាងផ្លាកលោហធាតុដោយកត់ត្រាឈ្មោះជនរងគ្រោះ និងការបង្ហាញធ្វើពលិកម្មទាំងអស់ ។
៥. រក្សាការពាររណ្ដៅកប់សាកសពនៅជើងឯក ។
៦. ផ្សព្វផ្សាយពីទ្រព្យធនរបស់ ឌុច ។
៧. កំណត់ឲ្យបានច្បាស់ថាតើនរណាជាអ្នកប្រតិបត្តិសំណាងថ្លៃខ្ជូចខាតនេះ ។

## ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៤

ហុន គឹមសួន បានចាប់ផ្ដើមថ្លែងសេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោលផ្នែកទីបួន ដោយនិយាយជាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៤ ។ លោកបានបន្តថ្លែងពីជាទិន្នន័យអំពីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ នាក់នៅក្នុងក្រុមរបស់លោក ។ អ្នកខ្លះអាចឆ្ងល់ថាតើលោក ហុន គឹមសួន កំពុងតែប្រើប្រាស់ពេលវេលាដ៏តម្លៃសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ឬយ៉ាងណា ។ បើទោះបីជាអ្នកខ្លះអាចនឹងកោតសរសើរលោក ហុន គឹមសួន សម្រាប់ការទទួលស្គាល់ចំពោះវត្តមានដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នេះក៏ដោយ ក៏រាល់អ្វីដែលលោកបាននិយាយមិនអាចក្លាយជាកត្តាបញ្ចុះបញ្ចូលដល់ការត្រិះរិះពិចារណារបស់ចៅក្រមឡើយ ។ ឌុច មើលទៅដូចជាមិនចាប់អារម្មណ៍អ្វីទាល់តែសោះចំពោះសេចក្ដីសន្និដ្ឋានរបស់លោក ហុន គឹមសួន ។ យ៉ាងណាមិញ ចំណុចបញ្ចប់សេចក្ដីសន្និដ្ឋានរបស់លោក ហុន គឹមសួន គឺពិតជាគំនិតមួយគួរឲ្យចាប់អារម្មណ៍ ដោយលោកបានស្នើថាប្រាក់បង់ថ្លៃចូលទស្សនាមន្ទីរស-២១ គួរតែយកមកឧបត្ថម្ភដល់សំណងថ្លៃខូចខាតនោះ ។

ព្យែរ អូលីវីយេ សួរមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមកពីប្រទេសបារាំងបានថ្លែងសេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោលចុងក្រោយបង្អស់ក្នុងថ្ងៃនេះ ។ លោកបានកត់សម្គាល់ពីបរានុម័តដោយនិយាយថា ឌុច មានវត្តមាននៅក្នុងអង្គសវនាការនេះដោយគ្មានផលលំបាកអ្វីទាល់តែសោះ ចំណែកឯជនរងគ្រោះវិញ បានជួបប្រទះនូវបញ្ហាជាច្រើនក្នុងការធានាឲ្យមានជាការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី ។ លោកបាននិយាយថា ចំនួនដើមបណ្ដឹងរដ្ឋប្បវេណីសរុបដែលមានចំនួន៩៤នាក់នេះ បានកាត់បន្ថយក

ម្រិតនៃទ្រឹស្តីរបស់បរានុម័តនេះ ។ ស្របពេលដែលជនរងគ្រោះកំពុងតែជាប់ពាក់ព័ន្ធនឹងសាសនាព្រះពុទ្ធជាមួយនឹងកម្ម ការចាប់កំណើតសារជាថ្មី និងគោលគំនិត«បំភ្លេចរឿងចោល»នោះ ប្រទេសរបស់ជនរងគ្រោះទាំងនេះ ដែលធ្លាប់ត្រូវបានដឹកនាំដោយទាហានខ្មែរក្រហមក៏កំពុងតែប្រឈមមុខនឹងបញ្ហាដែលនឹងជួបប្រទះនាពេលអនាគត ស្របពេលដែលប្រទេសនេះ កំពុងតែព្យាយាមរក្សាការចង់ចាំឲ្យនៅឋិតថេរ ។ ទើបតែប៉ុន្មានខែថ្មីៗនេះទេ ដែលព័ត៌មានស្តីពីមន្ទីរស-២១ត្រូវបានដាក់បញ្ចូលក្នុងសៀវភៅសិក្សាតាមសាលារៀន ។

ព្យែរ អូលីវីយេ ស្តូរ បានបញ្ជាក់ថា ការយំសម្រក់ទឹកភ្នែកជាសាធារណៈរបស់ ឌុច គឺមានលក្ខណៈចម្លែកខុសពីវប្បធម៌ព្រះពុទ្ធសាសនា ដែលទទួលស្គាល់ការរួចរស់មានជីវិត ។ ដោយផ្លាស់ប្តូរមកកាន់សាសនាគ្រិស្ត ឌុច ច្បាស់ជាអនុវត្តទៅតាមភាពសមហេតុផលនៃការរួចរស់មានជីវិត ។ ឌុច បានព្យាយាមបង្ហាញពីភាពជាប់ពាក់ព័ន្ធ និងចូលខ្លួនរួមចំណែកក្នុងដំណើរនីតិវិធីរបស់អង្គជំនុំជម្រះសេចក្តីនេះ ។ ជនរងគ្រោះទាំងអស់ពិតជាមានអារម្មណ៍មិនល្អនៅក្នុងចិត្តឡើយ ។

លោកបានគូសបញ្ជាក់ថា ការអត់ឱនទោសរបស់ជនរងគ្រោះអាចនឹងដើរស្របគ្នានឹងចម្លើយសារភាពដ៏ស្មោះត្រង់ និងផ្ញើឡើងអស់ពីកម្លាំងកាយចិត្តតែប៉ុណ្ណោះ ។ ការអះអាងរបស់ ឌុច បន្ថែមដែលថាខ្លួនគ្រាន់តែជាជនបម្រើឲ្យយន្តការរបស់ខ្មែរក្រហមនោះ ពិតជាមានលក្ខណៈមិនសមហេតុផលឡើយ ។ ឌុច បានធ្វើឲ្យវិធីសាស្ត្រគ្រប់គ្រងនៅមន្ទីរម-១៣កាន់តែល្អប្រសើរខ្លាំងឡើង ដើម្បីអះអាងថាខ្លួនពូកែជាងអ្នកដទៃ និងបានឡើងតំណែងគ្រប់គ្រងមន្ទីរស-២១ ។ ឌុច មានអំណាចជួយជីវិតមនុស្ស ប៉ុន្តែ ឌុច ជ្រើសរើសមិនជួយស្រោចស្រង់ជីវិតមនុស្សទាំងនោះទេលើកលែងតែអ្នកថតរូប (អ្នកថតរូបពីជីវិតផ្ទាល់ខ្លួនរបស់ ឌុច រាប់ពាន់សន្លឹក) ពេទ្យធ្មេញ និងជាងគំនូរតែប៉ុណ្ណោះ ។ ប្រសិនបើ ឌុច អាចនឹងជួយស្រោចស្រង់ជីវិតមនុស្សបាន នោះមានន័យថា ឌុច ក៏អាចកម្ទេចជីវិតនោះបាន ដែរសូម្បីតែគ្រូបង្រៀនរបស់ ឌុច ជាដើម ។ ឌុច មិនមែនជាជនដែលត្រូវគេបោកប្រើយកប្រយោជន៍នោះទេ ។ ឌុច ត្រូវតែវិនិច្ឆ័យទោសថាជាឧក្រិដ្ឋជនប្រឆាំងនឹងមនុស្សជាតិ ។

ព្យែរ អូលីវីយេ ស្តូរ បានរៀបរាប់ពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។ បន្ទាប់មកទៀតលោកបានស្នើឲ្យមានការទទួលខុសត្រូវតាមបែបយុត្តិធម៌អន្តរជាតិគឺ (គណៈកម្មាការណូបែល ទាក់ទិន

នឹងការចោទប្រកាន់ និងការចេញសេចក្តីសម្រេចថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងត្រូវវិនិច្ឆ័យទោសឲ្យទទួលទណ្ឌកម្ម) ។

លោកប្រធានចៅក្រម និល ណុន បានប្រកាសថា ដំណើរការនីតិវិធីសម្រាប់ថ្ងៃពុធ ទី២៥ ខែវិច្ឆិកា នឹងត្រូវប្រគល់ជូនដល់សហព្រះរាជអាជ្ញាសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល ។